# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះបង្ហាញពី សូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន និងបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ នៅត្រីមាសទី ៣ ឆ្នាំ២០១៩។

ក្នុងចំណោម ៦ប្រទេសអាស៊ានជ្រើសរើស មានតែវៀតណាមមួយប៉ុណ្ណោះដែលមាន កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំ កើនដល់ ៧,៣% ធៀបនឹង ៦,៩% នៅត្រីមាសទី៣ ឆ្នាំ២០១៨។ សេដ្ឋកិច្ចឥណ្ឌូនេស៊ី មានស្ថិរភាព ដោយមានកំណើន ផសស ដល់ ៥,០% នៅត្រីមាសទី២ និង ទី៣ ឆ្នាំ២០១៩ ប៉ុន្តែកំណើននេះធ្លាក់ចុះ ០,១ឯកតាភាគរយ ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ និងធ្លាក់ចុះ ០,២ឯកតាភាគរយ ធៀបនឹងត្រីមាសទី៣ និងទី៤ ឆ្នាំ២០១៨។ កំណើននៅម៉ាឡេស៊ី ធ្លាក់ចុះ ០,៣ឯកតាភាគរយ ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៨, ធ្លាក់ចុះ ០,១ឯកតាភាគរយ ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ និង ធ្លាក់ចុះ ០,៥ឯកតាភាគរយ ធៀបនឹងត្រីមាសទី២។ សេដ្ឋកិច្ចសិង្ហបុរីងើបឡើងវិញបាន ០,៤ឯកតាភាគរយ ធៀបនឹងត្រីមាសមុនដែលមានអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ធ្លាក់ចុះដល់ ០,១% (៣,៩%នៅត្រីមាសទី២ ឆ្នាំ២០១៨) ប៉ុន្តែបើធៀបនឹងកាលពីមួយឆ្នាំមុន វាបានធ្លាក់ចុះអស់ ១,៧ឯកតាភាគរយ។ ផសស ថៃ កើនដល់ ២,៤% ឬកើន ០,១ឯកតាភាគរយធៀបនឹងត្រីមាសមុន ក្រោយបានរួមចុះនៅត្រីមាសទី១ និង ទី២ ឆ្នាំ២០១៩ បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៨ ដែលមានកំណើនដល់ ៣,៧%។

ក្នុងចំណោមសេដ្ឋកិច្ចជ្រើសរើសទាំងបួននៅអាស៊ី ចិនមានអត្រាកំណើនខ្ពស់ជាងគេ ដល់ ៦,០% ប៉ុន្តែកំណើននេះបានធ្លាក់ចុះអស់ ០,២ឯកតាភាគរយ ធៀបនឹងត្រីមាសមុន។ អត្រាកំណើនមានដល់ ២,៩% នៅហុងកុង, ២,០% នៅកូរ៉េខាងត្បូង, និង ៣,០% នៅតៃវ៉ាន់។ បើពិនិត្យក្នុងរយៈពេលវែង កំណើន ផសស ពិត នៅចិន បានធ្លាក់ចុះអស់ ៨ត្រីមាសបន្តបន្ទាប់តាំងពីកំណើន ៦,៩% នៅឆ្នាំ២០១៧។ កំណើននៅហុងកុងបានងើបឡើងវិញដល់ ២,៩% គឺដល់កម្រិតនៅត្រីមាសទី៣ ឆ្នាំ២០១៨ ក្រោយបានរួមចុះអស់ ៣ត្រីមាសបន្តបន្ទាប់។ កំណើននៅកូរ៉េខាងត្បូង បានរួមចុះអស់ ០,១ឯកតាភាគរយ ធៀបនឹងត្រីមាសមុន ក្រោយបានស្ទុះឡើងពីកម្រិតទាបបំផុតត្រឹម ១,៨% នៅត្រីមាសទី១ ឆ្នាំ២០១៩។ តៃវ៉ាន់មានកំណើនសេដ្ឋកិច្ចដល់ ៣,០% ដែលជាអត្រាខ្ពស់បំផុតលំដាប់ទី២ គិតតាំងពីត្រីមាសទី២ ឆ្នាំ២០១៨ ដែលមានកំណើនដល់ ៣,៣%។

កំណើន ផសស ពិត នៅតំបន់អឺរ៉ូ១២ បានឡើងចុះក្នុងចន្លោះពី ១,១% ដល់ ១,២% ក្នុង ៤ត្រីមាសចុងក្រោយនេះ ដែលបង្ហាញពីការធ្លាក់ចុះកំណើនអស់ ១,៣ឯកតាភាគរយ, ១,០ឯកតាភាគរយ និង ០,៤ឯកតាភាគរយ ធៀបនឹង ត្រីមាសទី១ ទី២ និង ទី៣ ឆ្នាំ២០១៨។ កំណើន ផសស ពិត នៅជប៉ុន កើនឡើងជាទៀងទាត់ដល់ ១,៧% ធៀបនឹងកម្រិតទាបបំផុតត្រឹម ០,០% នៅត្រីមាសទី៣ ឆ្នាំ២០១៨។ កំណើន ផសស ពិត នៅសហរដ្ឋអាមេរិក ធ្លាក់ចុះមកត្រឹម ២,១% ដែលកំណើនប្រចាំត្រីមាសទាបបំផុត គិតតាំងពីត្រីមាសទី១ ឆ្នាំ២០១៨ ដោយបានធ្លាក់ចុះអស់ ១,១ឯកតាភាគរយ ធៀបនឹងកម្រិតខ្ពស់បំផុតក្នុងរយៈពេល ៧ត្រីមាសនេះ ឬស្មើគ្នានឹងកំណើន ផសស ជាមធ្យមក្នុងឆ្នាំ២០១៣។

## អតិផរណាក្នុងពិភពលោក

អត្រាអតិផរណាក្នុង ៦ប្រទេសអាស៊ានជ្រើសរើស មិនមានការប្រែប្រួលដូចគ្នាទេ។ អតិផរណាបានកើនឡើងនៅ កម្ពុជា ឥណ្ឌូនេស៊ី និង ម៉ាឡេស៊ី ប៉ុន្តែថយចុះនៅ សិង្ហបុរី ថៃ និង វៀតណាម។ នៅកម្ពុជា អតិផរណាកើនដល់ ២,០% គឺកើនត្រឹម ០,២ឯកតាភាគរយ ធៀបនឹង ត្រីមាសទី២ ដែលមានអត្រាអតិផរណាទាបបំផុតក្នុងរយៈពេល ៧ត្រីមាសនេះ។ ឥណ្ឌូនេស៊ីមានអត្រាអតិផរណាខ្ពស់ជាងគេក្នុង ៣ត្រីមាសចុងក្រោយ ដោយកើនដល់ ៣,៤% នៅត្រីមាសទី៣ ដែលជាអត្រាអតិផរណាខ្ពស់បំផុតក្នុង រយៈពេល ៧ត្រីមាស គិតតាំងពីត្រីមាសទី១ ឆ្នាំ២០១៨ មក។ អតិផរណានៅម៉ាឡេស៊ី ឡើងដល់ ១,៣% គឺកើន ០,៧ឯកតាភាគរយ ធៀបនឹង ត្រីមាសទី២ ដែលមានត្រឹម ០,៦% និង ត្រីមាសទី១ ដែលមានបរិត្តផរណាដល់ ០,៣%។ នៅសិង្ហបុរី អត្រាអតិផរណាធ្លាក់ចុះដល់ ០,៥% ធៀបនឹង ០,៨% នៅត្រីមាសទី២ ប៉ុន្តែស្មើគ្នានឹង អត្រាអតិផរណានៅត្រីមាសទី១ ឆ្នាំ២០១៩ និង ត្រីមាសទី៤ ឆ្នាំ២០១៨។ គួរកត់សំគាល់ថា ក្នុងចំណោមប្រទេសអាស៊ាននានា សិង្ហបុរីមានអត្រាអតិផរណាទាបជាងគេ បន្ទាប់មកគឺ ថៃដែលមានអត្រាធ្លាក់ចុះដល់ ០,៦% ឬ ធ្លាក់ចុះអស់ ០,៥ឯកតាភាគរយ ធៀបនឹង ត្រីមាសទី២ ដែលមានអតិផរណារហូតដល់ ១,១% ឬអត្រាខ្ពស់បំផុតក្នុងរយៈពេល ៤ត្រីមាស។ អតិផរណានៅវៀតណាម ចុះដល់ ២,២% ឬធ្លាក់ចុះ ០,៥ឯកតាភាគរយ ធៀបនឹង ត្រីមាសទី២ និងធ្លាក់ចុះរហូតដល់ ២,៣ឯកតាភាគរយ ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០១៨ ដែលមានអត្រាអតិផរណារហូតដល់ ៤,៥% គឺខ្ពស់ជាងប្រទេសជ្រើសរើសឯទៀតទាំងអស់ ក្នុងរយៈពេល ៧ត្រីមាសចុងក្រោយ។

អតិផរណានៅចិន ឡើងដល់ ២,៩% ឬកើន ០,៣ឯកតាភាគរយ ធៀបនឹងត្រីមាសមុន, នៅហុងកុង វាកើន ០,៧ឯកតាភាគរយ រហូតដល់ ៣,៤% ដែលជាអត្រាអតិផរណាខ្ពស់បំផុតនៅហុងកុង គិតតាំងពីឆ្នាំ២០១៥ មក និងជាអត្រាខ្ពស់ជាងគេនៅប្រទេសអាស៊ីជ្រើសរើសទាំងអស់ក្នុងរយៈពេលដូចគ្នា។ អតិផរណានៅកូរ៉េខាងត្បូង មាននិន្នាការធ្លាក់ចុះជាទៀងទាត់ គិតតាំងពីត្រីមាសទី៣ ឆ្នាំ២០១៨ មក ដោយធ្លាក់ចុះរហូតដល់ ០,១% នៅត្រីមាសទី៣ ឆ្នាំ២០១៩ (ធ្លាក់ចុះអស់ ០,៦ឯកតាភាគរយ

---

អត្ថបទនេះ រៀបរៀងដោយលោក រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

ធៀបនឹងត្រីមាសមុន) ពោលគឺ ដល់កម្រិតទាបបំផុតគិតតាំងពីឆ្នាំ២០១៣ មក និងជាអត្រាអតិផរណាទាបជាងគេក្នុងចំណោមប្រទេសអាស៊ីជ្រើសរើសទាំងអស់ក្នុងរយៈពេលដូចគ្នា។ អតិផរណានៅតៃវ៉ាន់ បានឡើងចុះក្នុង ៤ត្រីមាសចុងក្រោយ ដោយនៅថេរត្រឹម ១,៦% បាន ៣ត្រីមាសបន្តបន្ទាប់ រហូតដល់ត្រីមាសទី៣ ឆ្នាំ២០១៨ ហើយនៅត្រីមាសទី៣ ឆ្នាំ២០១៩ នេះ វាចុះដល់ ០,៤% ធៀបនឹង ០,៨% នៅត្រីមាសមុន។

ក្នុងចំណោមប្រទេសឧស្សាហកម្មជ្រើសរើសនានា ជប៉ុនមានអត្រាអតិផរណាទាបជាងគេ គិតតាំងពីឆ្នាំ២០១៦ មក។ នៅត្រីមាសទី៣ ឆ្នាំ២០១៩ នេះ ជប៉ុនមានអត្រាអតិផរណា ០,៣% ឬធ្លាក់ចុះអស់ ០,៤ឯកតាភាគរយ ធៀបនឹងត្រីមាសមុន (០,៧%)។ នៅតំបន់អឺរ៉ូ១២ និងសហរដ្ឋអាមេរិក អត្រាអតិផរណាមាននិន្នាការស្រដៀងគ្នាក្នុង ៧ត្រីមាសចុងក្រោយ។ ធៀបនឹងត្រីមាសមុន អតិផរណានៅតំបន់អឺរ៉ូ១២ ធ្លាក់ចុះអស់ ០,៤ឯកតាភាគរយ ដល់ ១,០% ដែលជាអត្រាទាបបំផុតគិតតាំងពីឆ្នាំ២០១៧ មក ហើយនៅសហរដ្ឋអាមេរិក វាធ្លាក់ចុះអស់ ០,១ឯកតាភាគរយ ដល់ ១,៧% គឺស្មើគ្នានឹងត្រីមាសទី១ ឆ្នាំ២០១៩ និងជិតស្មើគ្នានឹងឆ្នាំ២០១៤ ។

## អត្រាប្ដូរប្រាក់

ទល់នឹងប្រាក់ដុល្លារ ប្រាក់រៀលបានចុះថ្លៃដល់ ៤.០៨៦,៨ រៀល/ដុល្លារ ធៀបនឹង ៤.០៥២,១រៀល/ដុល្លារ នៅត្រីមាសទី២ និង ៤.០០៦,៦រៀល/ដុល្លារនៅត្រីមាសទី១។ ដុល្លារសិង្ហបុរីមានស្ថិរភាពនៅកម្រិត ១,៤ដុល្លារសិង្ហបុរី/ដុល្លារអាមេរិក គិតតាំងពីត្រីមាសទី៣ ឆ្នាំ២០១៨ មក ក្រោយបានចុះថ្លៃពីកម្រិត ១,៣ដុល្លារសិង្ហបុរី/ដុល្លារអាមេរិក នៅត្រីមាសទី១ និង ទី២ ឆ្នាំ២០១៨។ ប្រាក់បាតថៃ បានឡើងថ្លៃដល់ ៣០,៧បាត/ដុល្លារ ដោយបាននៅថេរត្រឹម ៣១,៦បាត/ដុល្លារ ក្នុង ២ត្រីមាសមុន។ ប្រាក់ដុងវៀតណាម បានចុះថ្លៃដល់ ២៣.២៥៨,៣ដុង/ដុល្លារ ដោយមាននិន្នាការបន្តចុះថ្លៃតាំងពីកម្រិត ២២.៤៨៣,៩ដុង/ដុល្លារ នៅត្រីមាសទី២ ឆ្នាំ២០១៨ មក។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

ធៀបនឹងត្រីមាសទី២ ឆ្នាំ២០១៩ ប្រេងដូងប្រេង និងអង្ករបានឡើងថ្លៃ រីឯ ពោត កៅស៊ូ សណ្ដែកសៀង ប្រេងឆៅ សាំង និង ម៉ាស៊ូត បានចុះថ្លៃ។ ប្រេងដូងប្រេងបានឡើងថ្លៃ ០,៤% ហើយអង្ករឡើងថ្លៃ ២,៣% រីឯពោតបានចុះថ្លៃ ៣,៣%, កៅស៊ូចុះថ្លៃ ១០,៣%, សណ្ដែកសៀងចុះថ្លៃ ២,៣%, ប្រេងឆៅចុះថ្លៃ ៨,៣%, សាំងចុះថ្លៃ ៦,៩% ហើយ ម៉ាស៊ូតចុះថ្លៃ ៤,៣%។ ធៀបនឹងកាលពីមួយឆ្នាំមុន ពោតឡើងថ្លៃ ៧,៧%, កៅស៊ូឡើងថ្លៃ ១,៨% ហើយអង្ករឡើងថ្លៃ ៣,៥% រីឯ ប្រេងដូងប្រេងចុះថ្លៃ ៦,៨%, សណ្ដែកសៀងចុះថ្លៃ ១៣,០%, ប្រេងឆៅចុះថ្លៃ ១៩,៥%, សាំងចុះថ្លៃ ១៥,០% ហើយ ម៉ាស៊ូតចុះថ្លៃ ១៣,៦%។

តារាង១៖ កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៣-២០១៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.3 | 7.1 | 7.0 | 7.0 | 7.0 | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 6.3 | 5.2 | 4.8 | 5.0 | 5.1 | 5.1 | 5.3 | 5.2 | 5.2 | 5.1 | 5.0 | 5.0 |
| ម៉ាឡេស៊ី | 5.4 | 6.0 | 4.9 | 4.3 | 5.9 | 5.4 | 4.5 | 4.4 | 4.7 | 4.5 | 4.9 | 4.4 |
| សិង្ហបុរី | 1.3 | 3.0 | 2.0 | 2.0 | 3.8 | 4.4 | 3.9 | 2.2 | 2.2 | 1.3 | 0.1 | 0.5 |
| ថៃ | 6.8 | 1.6 | 2.8 | 3.2 | 3.8 | 4.8 | 4.6 | 3.3 | 3.7 | 2.8 | 2.3 | 2.4 |
| វៀតណាម | 5.2 | 5.9 | 6.6 | 6.1 | 6.6 | 7.4 | 6.8 | 6.9 | 7.6 | 6.8 | 6.7 | 7.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 7.8 | 7.3 | 7.0 | 6.7 | 6.9 | 6.8 | 6.7 | 6.5 | 6.4 | 6.4 | 6.2 | 6.0 |
| ហុងកុង | 2.9 | 2.3 | 2.3 | 1.7 | 2.8 | 4.7 | 3.5 | 2.9 | 1.3 | 0.6 | 0.5 | 2.9 |
| កូរ៉េខាងត្បូង | 2.1 | 3.4 | 2.6 | 2.6 | 3.0 | 2.8 | 2.9 | 3.2 | 3.2 | 1.8 | 2.1 | 2.0 |
| តៃវ៉ាន់ | 1.2 | 3.5 | 0.6 | 1.2 | 2.8 | 3.0 | 3.3 | 2.3 | 1.8 | 1.7 | 2.4 | 3.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | -0.5 | 0.7 | 1.3 | 1.6 | 2.3 | 2.5 | 2.2 | 1.6 | 1.1 | 1.2 | 1.1 | 1.2 |
| ជប៉ុន | 1.7 | 0.6 | 0.3 | 0.9 | 1.8 | 1.1 | 1.0 | 0 | 0.4 | 0.9 | 1.2 | 1.7 |
| សហរដ្ឋអាមេរិក | 2.1 | 2.4 | 2.3 | 1.6 | 2.3 | 2.8 | 2.9 | 3.0 | 3.1 | 3.2 | 2.3 | 2.1 |

Sources: International Monetary Fund; *Economist*; countries' statistics offices

តារាង២៖ អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៣-២០១៩ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 3.0 | 3.9 | 1.2 | 3.0 | 2.9 | 2.2 | 2.7 | 2.5 | 2.4 | 1.9 | 1.8 | 2.0 |
| ឥណ្ឌូនេស៊ី | 7.0 | 6.4 | 6.4 | 3.5 | 3.8 | 3.3 | 3.2 | 3.1 | 3.2 | 2.6 | 3.1 | 3.4 |
| ម៉ាឡេស៊ី | 2.1 | 3.2 | 2.1 | 2.1 | 3.9 | 1.8 | 1.3 | 0.4 | 0.3 | -0.3 | 0.6 | 1.3 |
| សិង្ហបុរី | 2.3 | 1.0 | -0.5 | -0.8 | 0.6 | 0.2 | 0.4 | 0.7 | 0.5 | 0.5 | 0.8 | 0.5 |
| ថៃ | 2.2 | 1.9 | -0.9 | 0.2 | 0.7 | 0.6 | 1.3 | 1.5 | 0.8 | 0.7 | 1.1 | 0.6 |
| វៀតណាម | 6.6 | 4.8 | 0.6 | 2.7 | 3.4 | 2.8 | 3.8 | 4.5 | 3.4 | 2.6 | 2.7 | 2.2 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 2.6 | 2.0 | 1.4 | 2.0 | 1.6 | 2.2 | 1.8 | 2.3 | 2.2 | 1.8 | 2.6 | 2.9 |
| ហុងកុង | 4.0 | 4.4 | 3.1 | 2.5 | 1.7 | 2.4 | 2.1 | 2.3 | 2.6 | 2.2 | 2.7 | 3.4 |
| កូរ៉េខាងត្បូង | 1.1 | 1.3 | 0.7 | 0.8 | 2.0 | 1.2 | 1.5 | 1.6 | 1.2 | 0.6 | 0.7 | 0.1 |
| តៃវ៉ាន់ | 0.8 | 1.5 | 0.6 | 1.4 | 0.6 | 1.6 | 1.6 | 1.6 | 0.9 | 0.3 | 0.8 | 0.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.4 | 0.0 | 0.3 | 1.5 | 1.3 | 1.7 | 2.1 | 1.9 | 1.4 | 1.4 | 1.0 |
| ជប៉ុន | 0.4 | 2.8 | 0.9 | -0.1 | 0.6 | 1.3 | 0.6 | 1.1 | 0.9 | 0.3 | 0.7 | 0.3 |
| សហរដ្ឋអាមេរិក | 1.5 | 1.6 | 0.0 | 1.2 | 2.1 | 2.2 | 2.7 | 2.6 | 2.2 | 1.7 | 1.8 | 1.7 |

Sources: International Monetary Fund; *Economist*; National Institute of Statistics

តារាង៣៖ អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៣-២០១៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4027.2 | 4037.6 | 4060.4 | 4053.6 | 4047.0 | 4012.4 | 4047.0 | 4073.7 | 4046.7 | 4006.6 | 4052.1 | 4086.8 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 10419.2 | 11850.2 | 13394.8 | 13338.3 | 13379.8 | 13576.1 | 13944.6 | 14600.2 | 14789.7 | 14127.8 | 14246.8 | 14117.6 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.1 | 3.3 | 3.9 | 4.1 | 4.3 | 3.9 | 3.9 | 4.1 | 4.2 | 4.1 | 4.1 | 4.2 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.3 | 1.3 | 1.4 | 1.4 | 1.4 | 1.3 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 30.7 | 32.5 | 34.2 | 35.3 | 33.9 | 31.6 | 31.9 | 33.0 | 32.8 | 31.6 | 31.6 | 30.7 |
| វៀតណាម (ដុង) | 20990.3 | 21138.2 | 21917.7 | 22507.5 | 22645.9 | 22749.5 | 22483.9 | 22675.7 | 22744.1 | 22902.9 | 23255.5 | 23258.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ័ន) | 6.1 | 6.2 | 6.3 | 6.6 | 6.8 | 6.4 | 6.4 | 6.8 | 6.9 | 6.7 | 6.8 | 7.0 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1095.0 | 1053.6 | 1131.9 | 1161.0 | 1130.5 | 1072.0 | 1079.0 | 1120.9 | 1127.7 | 1125.0 | 1165.4 | 1193.4 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 29.7 | 30.3 | 31.8 | 32.3 | 30.4 | 29.3 | 29.8 | 30.7 | 30.8 | 30.8 | 31.1 | 31.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 97.6 | 105.9 | 121.0 | 108.8 | 112.1 | 108.4 | 109.1 | 111.4 | 112.8 | 110.1 | 109.9 | 107.3 |

Sources: International Monetary Fund; *Economist*; National Bank of Cambodia

តារាង៤៖ ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១៣-២០១៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ពោត (US No.2) - USA (ដុល្លារ/តោន) | 259.4 | 192.9 | 169.8 | 159.2 | 154.5 | 163.7 | 173.3 | 157.9 | 162.8 | 167.5 | 175.9 | 170.1 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (ដុល្លារ/តោន) | 856.9 | 821.4 | 622.7 | 643.6 | 714.7 | 673.7 | 601.0 | 612.0 | 554.8 | 586.9 | 568.1 | 570.1 |
| កៅស៊ូ SMR 5 (ដុល្លារ/តោន) | 2575.3 | 1755.6 | 1392.7 | 1416.1 | 1688.3 | 1504.0 | 1433.3 | 1365.2 | 1303.1 | 1436.6 | 1549.5 | 1389.7 |
| អង្ករ (Thai 100% B) - បាងកក (ដុល្លារ/តោន) | 533.8 | 434.9 | 395.5 | 406.7 | 452.3 | 459.3 | 451.0 | 424.7 | 426.7 | 426.7 | 430.0 | 439.7 |
| សណ្ដែកសៀង (US No.1) - USA (ដុល្លារ/តោន) | 538.4 | 491.8 | 390.4 | 405.7 | 400.6 | 418.3 | 435.6 | 390.6 | 368.9 | 353.3 | 347.8 | 339.7 |
| ប្រេងឆៅ - OPEC spot (ដុល្លារ/ធុង) | 105.9 | 96.2 | 49.6 | 40.7 | 52.6 | 64.7 | 71.9 | 74.2 | 67.2 | 63.0 | 65.1 | 59.7 |
| សាំង - US Gulf Coast (សេនដុល្លារ/លីត្រ) | 71.2 | 65.6 | 41.0 | 35.2 | 42.4 | 47.9 | 53.3 | 54.1 | 42.9 | 40.9 | 49.4 | 46.0 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេនដុល្លារ/លីត្រ) | 78.4 | 71.5 | 41.7 | 34.8 | 42.9 | 51.0 | 55.6 | 56.6 | 52.2 | 49.5 | 51.1 | 48.9 |

Sources: Food and Agriculture Organisation; US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ក្នុង ៤ត្រីមាសចុងក្រោយនេះ មានការប្រែប្រួលគួរឲ្យកត់សំគាល់ក្នុង វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ដែលត្រូវបានអនុម័ត។ នៅត្រីមាសទី៣ ឆ្នាំ២០១៩ ការអនុម័តលើគម្រោងវិនិយោគសរុប កើន ៨,៩% ពីមួយឆ្នាំទៅមួយឆ្នាំ ដល់ ១.១៥៣,៥លានដុល្លារ ប៉ុន្តែតួលេខនេះបង្ហាញពីការធ្លាក់ចុះ ៥៧,០% និង ៤០,៤% ធៀបនឹងត្រីមាសទី២ និងត្រីមាសទី១ រៀងគ្នា។ គិតតាមវិស័យ ការអនុម័តវិនិយោគផ្នែកសេវាកម្ម កើន ៤០,៣% គឺជំរុញឡើងដោយសារ ការអនុម័តវិនិយោគលើសណ្ឋាគារនិងទេសចរណ៍ដែលកើន ១០,៨% ដល់ ៨០៨,៧ លានដុល្លារ។ លទ្ធផលក្នុងត្រីមាសទី៣ នេះ បង្ហាញពី ការថយចុះរហូតដល់ ៥០,០% និង ៦៧,៩% ធៀបនឹងត្រីមាសទី១ និងត្រីមាសទី២។ ការអនុម័តវិនិយោគផ្នែកឧស្សាហកម្ម កើនដល់ ៣០២,០លានដុល្លារ ឬកើន ៣,១% ធៀបនឹងត្រីមាសទី១ និង កើនរហូតដល់ ១៦៥,៦% (ដោយសារកំណើន ៣៧,៥% ខាងផ្នែកសម្លៀកបំពាក់) ធៀបនឹងត្រីមាសទី២ ប៉ុន្តែវាធ្លាក់ចុះ ២៦,០% ធៀបនឹងកាលពីមួយឆ្នាំមុន។ ការអនុម័តវិនិយោគផ្នែកកសិកម្ម ធ្លាក់ចុះ ៩៥,៨% ពីមួយឆ្នាំទៅមួយឆ្នាំ ឬធ្លាក់ចុះ ៨៩,០ ធៀបនឹងត្រីមាសទី១ និងចុះ ៩៦,១% ធៀបនឹងត្រីមាសទី២។

ចំនួនភ្ញៀវទេសចរអន្តរជាតិមកដល់កម្ពុជាសរុប កើនដល់ ១.៤៧៥.៨០០នាក់ ឬកើន ៧,៤% ពីមួយឆ្នាំទៅមួយឆ្នាំ និងកើន ១,០% ធៀបនឹងត្រីមាសទី២ ប៉ុន្តែធ្លាក់ចុះ ២១,៤% ធៀបនឹងត្រីមាសទី១។ ទេសចរមកពីចិន មានចំនួនភាគរយខ្ពស់ជាងគេរហូតដល់ ៣៨,៨% នៃទេសចរអន្តរជាតិមកដល់សរុប ហើយបន្ទាប់មក គឺ ទេសចរមកពី វៀតណាម (១៦,០%) ថៃ (៧,៧%) ជប៉ុន (៣,៣%) កូរ៉េខាងត្បូង (៣,២%) ម៉ាឡេស៊ី (៣,២%) សហរដ្ឋអាមេរិក (៣,១%) បារាំង (២,២%) និង អង់គ្លេស (២,០%)។ គួរកត់សំគាល់ថា ទេសចរមកពីចិន បានធ្លាក់ចុះជាទៀងទាត់ តាំងពីប្រមាណ ៦៨៣.៤០០នាក់ នៅត្រីមាសទី១ ដល់ ៦០៩.១០០នាក់ នៅត្រីមាសទី២ និង ៥៧២.៥០០នាក់ នៅត្រីមាសទី៣។

នៅត្រីមាសទី៣ នេះ ជញ្ជីងពាណិជ្ជកម្មនៅមានឱនភាពរហូតដល់ ៨២៧,៥លានដុល្លារ ដែលបង្ហាញនូវកំណើន ៤០៨,៣% ពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែការធ្លាក់ចុះអស់ ៥៧,៦% ធៀបនឹងកម្រិតខ្ពស់បំផុតដល់ ១.៩៩០,៦លានដុល្លារ នៅត្រីមាសទី២ នៅពេលដែលតម្លៃនាំចេញឡើងដល់ ៣.៣៧៩,០លានដុល្លារ ហើយតម្លៃនាំចូលឡើងដល់ ៥.៣២៨,៦លានដុល្លារ។ តម្លៃនាំចេញកើនឡើងយ៉ាងទៀងទាត់ តាំងពី ៣.១៣៥,៤លានដុល្លារ នៅត្រីមាសទី៤ ឆ្នាំ២០១៨ រហូតដល់ ៤.២៦៣,៩លានដុល្លារ នៅត្រីមាសទី៣ ឆ្នាំ២០១៩ (កំណើន ១១,៨% ពីមួយឆ្នាំទៅមួយឆ្នាំ)។ ការនាំចេញសម្លៀកបំពាក់ កើនដល់ ៣.១៤៣,៨ លានដុល្លារ ឬកើន ៩,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ គិតតាមប្រទេសគោលដៅនាំចេញ ហើយធៀបនឹងត្រីមាសមុន ការនាំចេញសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិក កើន ២៥,៤% (ដល់ ១.០០៦,៥លានដុល្លារ), ទៅសហភាពអឺរ៉ុប កើន ២០,៥% (ដល់ ៩៦៥,៤លានដុល្លារ), ទៅជប៉ុន កើន ៦៥,៦% (ដល់ ២៩១,២លានដុល្លារ), ទៅអង់គ្លេស កើន ៣៨,០% (ដល់ ២៧២,៩លានដុល្លារ), ទៅអាស៊ាន កើន ១៦,៧% (ដល់ ៤៨,២លានដុល្លារ), និងទៅប្រទេសផ្សេងៗទៀត កើន ១០,៣% (ដល់ ៥៥៩,៧លានដុល្លារ)។ ការនាំចេញគ្រឿងអេឡិចត្រូនិក កើន ៧០,៦% ពីមួយឆ្នាំទៅមួយឆ្នាំ និង កើន ១៤,៩% ធៀបនឹងត្រីមាសទី២។ ការនាំចេញគ្រឿងបង្គុំយានយន្ត ក៏កើនបាន ៤៨,៤% ពីមួយឆ្នាំទៅមួយឆ្នាំ និងកើន ២៤,៧% ធៀបនឹងត្រីមាសមុន។ ការនាំចេញផលិតផលកសិកម្ម ធ្លាក់ចុះ ១,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែកើន ១៨,៧% ធៀបនឹងត្រីមាសមុន ដោយសារកំណើនការនាំចេញ កៅស៊ូ ឈើ និង អង្ករ។

ការនាំចូលសរុបកើនដល់ ៥.០៩១,៤លានដុល្លារ ឬកើន ២៨,០% ពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែធ្លាក់ចុះ ៤,៥% ធៀបនឹងត្រីមាសមុន (៥.៣២៨,៦លានដុល្លារ)។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនេះ ជំរុញឡើងដោយសារកំណើនការនាំចូល សាំង (កើន ៣៦,៣% ដល់ ១១៨,៦លានដុល្លារ), ម៉ាស៊ូត (២,៧% ដល់ ១៦៦,៤លានដុល្លារ), សម្ភារសំណង់ (៦៦,៧% ដល់ ២៧១,២លានដុល្លារ), និងទំនិញនាំចូលផ្សេងៗទៀត (២៧,២% ដល់ ៤.៥៣៥,២លានដុល្លារ)។ ការនាំចូលបានថយចុះធៀបនឹងត្រីមាសមុន ដោយសារការនាំចូល ម៉ាស៊ូតធ្លាក់ចុះ ៣៣,៥% និង ទំនិញផ្សេងៗទៀតធ្លាក់ចុះ ៤,១%។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៣ ឆ្នាំ២០១៩ ចំណូលសរុបរបស់រដ្ឋាភិបាល កើនដល់ ៦.៣៦៤,៥ប៊ីលានរៀល ឬកើន ៣៦,៣% ពីមួយឆ្នាំទៅមួយឆ្នាំ ក្រោយបានធ្លាក់ចុះ ៩,៥% នៅត្រីមាសទី៤ ឆ្នាំ២០១៨ ប៉ុន្តែកើនបាន ០,១% ធៀបនឹងត្រីមាសមុន។ ចំណូលចរន្ត កើន ៣៦,៤% ពីមួយឆ្នាំទៅមួយឆ្នាំ ហើយកើន ១៣,៨% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៨ និងកើន ២៤,៥% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ ប៉ុន្តែធ្លាក់ចុះ ០,២% ធៀបនឹងត្រីមាសទី២។ ចំណូលពន្ធ និងពន្ធក្នុងស្រុក មាននិន្នាការស្រដៀងគ្នា។ ចំណូលពន្ធឡើងខ្ពស់បំផុតដល់ ៥.៦៦៣,៥ប៊ីលានរៀល នៅត្រីមាសទី២

អត្ថបទនេះ រៀបរៀងដោយលោក រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និង ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

រួចហើយធ្លាក់ចុះដល់ ៥.៤១៥,១ប៊ីលានរៀល នៅត្រីមាសទី៣។ ពន្ធក្នុងស្រុក ក្រោយបានឡើងខ្ពស់បំផុតនៅត្រីមាសទី២ បានរួមចុះវិញអស់ ៦,៣% ដល់ ៤.៦៣៤,១ប៊ីលានរៀល។ ចំណូលមិនមែនពន្ធ កើនដល់ ៨៩៤,១ប៊ីលានរៀល ឬកើន ៤៥,៣% ពីមួយឆ្នាំទៅមួយឆ្នាំ, កើន ៦៤,៨% ធៀបនឹងត្រីមាសទី១, និងកើន ៣៥,៧% ធៀបនឹងត្រីមាសទី២, ប៉ុន្តែធ្លាក់ចុះ ៤,៥% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៨។ ចំណូលជាមូលធន កើន ២៣,៩% ពីមួយឆ្នាំទៅមួយឆ្នាំ និងកើន ៥៨,៣% ធៀបនឹងត្រីមាសមុន។

ចំណាយសរុបកើនពី ៤.១៥០,៤ប៊ីលានរៀល នៅត្រីមាសទី១ ដល់ ៤.៩៩៧,៦ប៊ីលានរៀល នៅត្រីមាសទី២ និងដល់ ៥.៣៨៦,៥ប៊ីលានរៀល នៅត្រីមាសទី៣ (ធ្លាក់ចុះ ៨,១% ពីមួយឆ្នាំទៅមួយឆ្នាំ)។ ចំណាយជាមូលធន ធ្លាក់ចុះ ២,៥% ធៀបនឹងត្រីមាសទី២ ដល់ ១.៣៥៨,៦ប៊ីលានរៀល និងធ្លាក់ចុះ ៣១,៣% ធៀបនឹងត្រីមាសទី៣ ឆ្នាំមុន។ ចំណាយចរន្ត កើន ២៨,៩% ធៀបនឹងត្រីមាសទី១, កើន ១១,៧% ធៀបនឹងត្រីមាសទី២ និងកើន ៣,៧% ពីមួយឆ្នាំទៅមួយឆ្នាំ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៣ ឆ្នាំ២០១៩ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុប (CPI) នៅភ្នំពេញ ធ្លាក់ចុះអស់ ០,១ឯកតាភាគរយ ក្រោយបាននៅថេរត្រឹម ១,៩% ក្នុង ២ត្រីមាសមុន។ ធៀបនឹងត្រីមាសមុន សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សម្រាប់ស្បៀងអាហារ និងភេសជ្ជៈមិនមែនស្រា ធ្លាក់ចុះ ០,៥ឯកតាភាគរយ ហើយសម្រាប់ថ្លៃដឹកជញ្ជូនវាកើន ២,៣ឯកតាភាគរយ ពីលើការធ្លាក់ចុះរបស់វា។

ធៀបនឹងត្រីមាសមុន ប្រាក់រៀលចុះថ្លៃ ០,៩% ទល់នឹងប្រាក់ដុល្លារ ដល់ ៤.០៨៦,៨រៀល/ដុល្លារ, ចុះថ្លៃ ៣,៧% ទល់នឹងប្រាក់បាតថៃ ដល់ ១៣៣,៧រៀល/បាត និងចុះថ្លៃ ១,១% ទល់នឹងប្រាក់ដុងវៀតណាម ដល់ ១៧,៧រៀល/១០០ដុង។

មាសឡើងថ្លៃក្នុង ៥ត្រីមាសចុងក្រោយ តាំងពី ១៤៦,១ ដុល្លារ/ជី នៅត្រីមាសទី៣ ឆ្នាំ២០១៨ រហូតដល់ ១៧៥,៧ ដុល្លារ/ជី នៅត្រីមាសទី៣ ឆ្នាំ២០១៩។

នៅត្រីមាសទី៣ ឆ្នាំ២០១៩ ម៉ាស៊ូត ចុះថ្លៃដល់ ៣.៤៩៩,៧ រៀល/លីត្រ ធៀបនឹង ៣.៥៩៥,៤រៀល/លីត្រ នៅត្រីមាសមុន។ សាំង ចុះថ្លៃដល់ ៣.៦២៩,៣រៀល/លីត្រ ធៀបនឹង ៣.៧៧០,២ រៀល/លីត្រ នៅត្រីមាសទី២។

## ប្រាក់ចំណូលប្រចាំថ្ងៃមធ្យមពិតរបស់ពលករងាយរងគ្រោះ

ផ្នែកនេះ ពិពណ៌នាដោយសង្ខេបពីស្ថានភាពរបស់ពលករងាយរងគ្រោះ ដោយផ្អែកលើអង្កេតនៅខែវិច្ឆិកា ២០១៩។ ជារួម អ្នករត់តុភោជនីយដ្ឋាន មានប្រាក់ចំណូលប្រចាំថ្ងៃទាបជាងគេ បន្ទាប់មកគឺ អ្នកស៊ីឈ្នួលធ្វើស្រែ ដែលរកបានតិចជាង ១០.០០០ រៀល/ថ្ងៃ។ កម្មករសំណង់មានជំនាញ រកចំណូលប្រចាំថ្ងៃបានខ្ពស់ជាងគេ បន្ទាប់មកគឺ កម្មករសំណង់គ្មានជំនាញ អ្នកលីសែង អ្នកលក់បន្លែតូចតាច កម្មកររោងចក្រកាត់ដេរ អ្នករត់ម៉ូតូឌុប អ្នករើសអេតចាយ និង អ្នករត់ស៊ីក្លូ។ ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពលករងាយរងគ្រោះពីរប្រភេទ ពោលគឺ អ្នកលក់បន្លែតូចតាច និង កម្មករសំណង់គ្មានជំនាញ បានធ្លាក់ចុះធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន រីឯពលករងាយរងគ្រោះប្រភេទឯទៀតបានកើនចំណូលប្រចាំថ្ងៃ។

ក្នុងចំណោមពលករងាយរងគ្រោះទាំងអស់ កម្មករសំណង់មានជំនាញរកចំណូលប្រចាំថ្ងៃបានខ្ពស់ជាងគេ ដល់ ២៧.២២៥ រៀល បន្ទាប់មកគឺ កម្មករសំណង់គ្មានជំនាញ (១៨.៨១៤រៀល) អ្នកលីសែង (១៨.៨០២រៀល) អ្នកលក់បន្លែតូចតាច (១៨.៦៥១ រៀល) កម្មកររោងចក្រកាត់ដេរ (១៦.៥៧៨រៀល) អ្នករត់ម៉ូតូឌុប (១៤.៩០៤រៀល) អ្នករើសអេតចាយ (១៣.០៩៩រៀល) អ្នករត់ស៊ីក្លូ (១២.០៤៦រៀល) អ្នកស៊ីឈ្នួលធ្វើស្រែ (៩.៣៧៦រៀល) និង អ្នករត់តុភោជនីយដ្ឋាន (៨.៧២៤រៀល)។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប្រាក់ចំណូលប្រចាំថ្ងៃបានកើនឡើងសម្រាប់ កម្មករសំណង់មានជំនាញ (២,៤%) អ្នកលីសែង (២១,៧%) កម្មកររោងចក្រកាត់ដេរ (៥,១%) អ្នករើសអេតចាយ (៤,២%) អ្នករត់ស៊ីក្លូ (១៤,៧%) និង អ្នកស៊ីឈ្នួលធ្វើស្រែ (៤,៤%) ប៉ុន្តែវាបានធ្លាក់ចុះសម្រាប់ អ្នកលក់បន្លែតូចតាច (១១,៣%) និង កម្មករសំណង់គ្មានជំនាញ(០,៥%)។

ក្នុងចំណោមពលករក្នុងអង្កេត ៣៦០នាក់ក្នុង ៩ប្រភេទការងារ (លើកលែងតែកម្មកររោងចក្រកាត់ដេរចេញ) មានភាគច្រើនណាស់ដែលធ្វើចំណាកស្រុកពីខេត្ត មកធ្វើការនៅក្រុងភ្នំពេញ ឬសៀមរាប។ អ្នកទាំងនេះមកពី ព្រៃវែង (៣១,៤%) ស្វាយរៀង (២៤,៤%) តាកែវ (១៣,១%) កំពង់ស្ពឺ (១១,៧%) កណ្តាល (៨,៦%) កំពត (៣,៦%) កំពង់ចាម (២,៨%) កោះកុង (០,៦%) ភ្នំពេញ (០,៦%) ក្រចេះ (០,៣%) និង បន្ទាយមានជ័យ (០,៣%)។ ក្នុងចំណោមពលករ ៣៦០នាក់នេះ មាន ៧១,៩% មកពីគ្រួសារធំៗមានសមាជិកដល់ ៤-៧នាក់, ៨៨,៦% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ, និង ៦៧,២% ធ្វើចំណាកស្រុកតែម្នាក់ឯងមកធ្វើការនៅទីក្រុង។ តបនឹងសំណួរថា តើប្រាក់ចំណូលរបស់អ្នកអាចទ្រទ្រង់ជីវភាពគ្រួសារបានឬទេ? មាន ៥,៦% ប្រាប់ថាទ្រទ្រង់បាន, ៣,៣% ថាមិនបានទេ, និង ៩១,១% ថាបានមួយភាគ។ គិតជាមធ្យម ប្រាក់ចំណូលរបស់ពលករចំណាយជាសំខាន់លើ ស្បៀងអាហារ (៩៦,៦%) កន្លែងស្នាក់នៅ (០,៣%) ដឹកជញ្ជូន (០,៥) និង ចំណាយផ្សេងៗទៀត (២,៦%)។

## តារាង១៖ គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១៣-១៩

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 930.5 | 56.5 | 169.8 | 117.1 | 62.9 | 99.5 | 30.4 | 45.2 | 39.8 | 17.2 | 48.2 | 1.9 |
| ឧស្សាហកម្ម | 3256.9 | 1002.5 | 1014.7 | 1436.4 | 982.2 | 259.6 | 193.4 | 408.2 | 325.0 | 292.9 | 113.7 | 302.0 |
| *. សម្លៀកបំពាក់* | 324.1 | 393.5 | 225.2 | 380.7 | 211.1 | 53.2 | 31.4 | 49.9 | 52.8 | 73.9 | 34.4 | 47.3 |
| សេវាកម្ម | 140.7 | 622.6 | 2734.4 | 1664.3 | 3858.6 | 110.2 | 2156.2 | 605.5 | 1479.8 | 1625.6 | 2518.2 | 849.7 |
| *. សណ្ឋាគារ និងទេសចរណ៍* | 106.0 | 446.9 | 98.6 | 1366.9 | 2759.6 | 75.2 | 106.6 | 68.3 | 1333.9 | 1618.8 | 2518.2 | 808.7 |
| សរុប | 4328.5 | 1583.9 | 3918.9 | 3217.7 | 4903.7 | 469.3 | 2380.0 | 1058.9 | 1844.7 | 1935.6 | 2680.1 | 1153.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 310.5 | 407.2 | -55.5 | 74.2 | 4.9 | 38.5 | -57.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 90.1 | -63.4 | 147.4 | -17.9 | 52.4 | 257.2 | 44.0 | -64.8 | 1513.7 | 312.5 | 12.6 | 8.9 |

Note: Including expansion project approvals. Source: Cambodian Investment Board

## តារាង២៖ តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ ផ្ទះ និងផ្ទះល្វែង | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 227.3 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣៖ ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១៣-១៩

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| ចិន | 463.1 | 560.3 | 694.7 | 830.0 | 1210.8 | 505.9 | 425.8 | 509.0 | 583.7 | 683.4 | 609.1 | 572.5 |
| វៀតណាម | 854.1 | 905.8 | 987.8 | 959.7 | 835.4 | 186.8 | 199.9 | 197.7 | 215.9 | 186.9 | 214.8 | 235.7 |
| កូរ៉េខាងត្បូង | 435.0 | 424.4 | 395.3 | 357.2 | 345.0 | 126.1 | 48.5 | 483.9 | 78.8 | 95.7 | 43.6 | 47.4 |
| ថៃ | 221.3 | 279.5 | 349.9 | 398.1 | 394.9 | 83.7 | 76.1 | 75.5 | 147.0 | 97.9 | 76.3 | 113.9 |
| សហរដ្ឋអាមេរិក | 185.0 | 191.4 | 217.5 | 238.7 | 256.5 | 79.1 | 54.6 | 47.7 | 69.5 | 79.0 | 53.2 | 45.5 |
| ជប៉ុន | 206.9 | 215.8 | 193.3 | 191.6 | 203.4 | 59.0 | 38.7 | 47.7 | 65.1 | 60.2 | 40.4 | 48.9 |
| បារាំង | 131.5 | 141.1 | 145.7 | 150.3 | 166.4 | 56.6 | 29.4 | 33.5 | 51.4 | 59.4 | 27.3 | 32.9 |
| ចក្រភពអង់គ្លេស | 123.9 | 133.3 | 154.3 | 159.5 | 171.2 | 51.2 | 33.7 | 33.0 | 44.5 | 59.4 | 29.7 | 28.5 |
| ម៉ាឡេស៊ី | 130.7 | 144.4 | 149.4 | 152.8 | 179.3 | 44.8 | 41.0 | 49.4 | 65.8 | 48.7 | 43.2 | 46.5 |
| តាមផ្លូវអាកាស | 2017.7 | 2273.5 | 2476.0 | 2778.0 | 3312.7 | 1157.6 | 846.5 | 954.8 | 1137.9 | 1299.1 | 1054.8 | 1039.9 |
| តាមផ្លូវគោក និងទឹក | 2192.5 | 2229.3 | 2299.2 | 2331.4 | 2289.4 | 553.6 | 443.9 | 419.6 | 687.1 | 578.7 | 405.8 | 436.0 |
| សរុប | 4210.2 | 4502.8 | 4775.2 | 4980.4 | 5602.2 | 1711.3 | 1290.4 | 1374.4 | 1825.0 | 1877.9 | 1460.6 | 1475.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 1.3 | -24.6 | 6.5 | 32.8 | 2.9 | -22.2 | 1.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 17.5 | 7.0 | 6.1 | 4.3 | 12.5 | 129.3 | -158.8 | 9.9 | 8.0 | 9.7 | 13.2 | 7.4 |

Source: Ministry of Tourism

## តារាង៤៖ ការនាំចេញ និងនាំចូល ឆ្នាំ២០១៣-១៩ *

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 6982.4 | 8106.0 | 9256.4 | 10043.3 | 10772.9 | 2834.6 | 3000.2 | 3813.7 | 3135.4 | 3222.7 | 3379.0 | 4263.9 |
| សម្លៀកបំពាក់ | 5386.1 | 5960.5 | 6827.0 | 7308.0 | 8020.3 | 2092.1 | 2240.6 | 2871.0 | 2302.3 | 2463.4 | 2526.3 | 3143.8 |
| - *សហរដ្ឋអាមេរិក* | 2075.2 | 1963.6 | 2009.4 | 1831.5 | 1923.8 | 538.4 | 573.9 | 743.5 | 627.4 | 739.8 | 802.9 | 1006.5 |
| - *សហភាពអឺរ៉ុប* | 1969.6 | 2403.7 | 2903.9 | 2928.7 | 2782.2 | 670.1 | 805.2 | 916.7 | 763.4 | 719.2 | 801.1 | 965.4 |
| - *អាស៊ាន* | 60.2 | 83.3 | 103.4 | 98.4 | 106.9 | 28.6 | 32.7 | 33.0 | 41.1 | 38.1 | 41.3 | 48.2 |
| - *ជប៉ុន* | 278.7 | 383.1 | 524.2 | 655.5 | 701.2 | 224.7 | 165.2 | 276.6 | 224.3 | 262.9 | 175.8 | 291.2 |
| - *ចក្រភពអង់គ្លេស* | - | - | - | 439.8 | 904.0 | 219.5 | 203.9 | 382.5 | 201.1 | 211.5 | 197.7 | 272.9 |
| - *ប្រទេសផ្សេងៗ* | 1002.9 | 1126.8 | 1286.3 | 1354.2 | 1602.2 | 410.9 | 459.7 | 518.8 | 445.0 | 491.7 | 507.5 | 559.7 |
| គ្រឿងអេឡិចត្រូនិក | - | - | - | - | 380.0 | 76.2 | 90.9 | 83.4 | 78.3 | 71.9 | 123.8 | 142.3 |
| គ្រឿងយានយន្ត | - | - | - | - | 11.6 | 11.9 | 13.1 | 15.3 | 54.1 | 20.4 | 18.2 | 22.7 |
| កសិកម្ម | 554.5 | 624.4 | 548.8 | 534.1 | 706.4 | 205.9 | 166.0 | 213.6 | 265.5 | 210.4 | 177.7 | 211.0 |
| - *កៅស៊ូ* | 175.2 | 153.9 | 165.4 | 165.3 | 273.5 | 52.4 | 36.5 | 59.7 | 69.1 | 43.8 | 42.2 | 60.0 |
| - *ឈើ* | 73.6 | 132.0 | 46.3 | 47.2 | 100.5 | 30.0 | 34.0 | 42.0 | 36.3 | 22.2 | 35.2 | 42.4 |
| - *ត្រី* | 1.2 | 0.8 | 0.5 | 0.6 | 0.6 | 1.0 | 0.1 | 0.1 | 0.1 | 0.1 | 0.1 | 0.1 |
| - *អង្ករ* | 262.3 | 248.5 | 315.3 | 300.8 | 255.1 | 106.7 | 71.8 | 88.7 | 146.4 | 122.4 | 72.2 | 84.5 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 42.4 | 89.1 | 21.3 | 20.2 | 76.7 | 15.8 | 23.6 | 23.2 | 13.6 | 21.9 | 28.1 | 24.1 |
| ផ្សេងៗ | 1088.2 | 1520.1 | 1880.2 | 2201.2 | 1654.7 | 448.6 | 489.6 | 630.4 | 435.2 | 456.6 | 532.9 | 744.0 |
| ការនាំចូលសរុប | 8639.4 | 10295.4 | 11494.5 | 15013.4 | 16815.4 | 4244.5 | 4496.0 | 3976.5 | 4187.6 | 4437.7 | 5328.6 | 5091.4 |
| សាំង | 306.4 | 334.7 | 377.3 | 384.8 | 256.7 | 64.9 | 60.8 | 87.0 | 107.8 | 121.1 | 117.1 | 118.6 |
| ម៉ាស៊ីត | 569.1 | 602.3 | 607.8 | 709.1 | 472.9 | 102.0 | 116.9 | 162.0 | 213.2 | 228.2 | 250.2 | 166.4 |
| សម្ភារសំណង់ | 80.8 | 117.6 | 164.4 | 253.2 | 304.3 | 100.7 | 138.7 | 162.7 | 162.5 | 170.8 | 231.4 | 271.2 |
| ផ្សេងៗ | 7682.6 | 9240.7 | 10345.1 | 13666.3 | 15781.6 | 3976.9 | 4179.7 | 3564.8 | 3704.2 | 3917.7 | 4729.9 | 4535.2 |
| ជញ្ជីងពាណិជ្ជកម្ម | -1610.9 | -2184.3 | -2238.1 | -4970.0 | -5974.1 | -1409.9 | -1495.9 | -162.8 | -1052.3 | -1215.0 | -1990.6 | -827.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | | 4.6 | 7.1 | 28.1 | -19.8 | 7.0 | 2.6 | 24.4 |
| ការនាំចេញសរុប | - | - | - | - | | 0.3 | 5.8 | 27.1 | -17.8 | 2.8 | 7.8 | 26.2 |
| ការនាំចូលសរុប | - | - | - | - | | 24.0 | 5.9 | -11.6 | 5.3 | 6.0 | 27.2 | -4.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 7.4 | 10.7 | 14.5 | 7.0 | 9.7 | 12.7 | 19.6 | 25.4 | 15.1 | 17.7 | 12.8 | 9.5 |
| ការនាំចេញសរុប | 14.3 | 16.1 | 14.2 | 8.5 | 7.9 | 23.7 | 14.2 | 23.1 | 11.0 | 13.7 | 12.6 | 11.8 |
| ការនាំចូលសរុប | 15.4 | 19.7 | 11.7 | 30.6 | 12.0 | 33.8 | -24.0 | -7.6 | 22.3 | 4.6 | 18.5 | 28.0 |

Note: Import data include tax-exempt imports.

Sources: Department of Trade Preference Systems, Ministry of Commerce; Customs and Excise Department, Ministry of Economy and Finance website

## តារាង៥៖ ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០១៣-១៩ (ប៊ីលានរៀល)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ចំណូលសរុប | 8255.2 | 10543.4 | 11879.9 | 14201.5 | 16582.0 | 4357.6 | 5080.6 | 4670.3 | 5634.6 | 5097.5 | 6357.1 | 6364.5 |
| ចំណូលចរន្ត | 8233.2 | 10359.4 | 11759.0 | 14088.7 | 16481.4 | 4344.8 | 5035.2 | 4625.6 | 5543.5 | 5066.8 | 6322.2 | 6309.2 |
| ចំណូលពន្ធ | 7198.1 | 8995.2 | 10502.4 | 12196.5 | 14314.3 | 3984.9 | 4425.4 | 4010.2 | 4598.7 | 4524.3 | 5663.5 | 5415.1 |
| ពន្ធក្នុងស្រុក | 5728.1 | 7226.5 | 8591.7 | 10185.8 | 12338.7 | 3469.8 | 3850.4 | 3424.9 | 3903.2 | 3904.9 | 4944.9 | 4634.1 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1470.0 | 1822.7 | 1910.7 | 2010.7 | 1875.6 | 515.2 | 575.0 | 585.2 | 695.4 | 619.4 | 718.6 | 781.0 |
| ចំណូលមិនមែនពន្ធ | 1035.2 | 1310.3 | 1256.6 | 1892.2 | 2167.2 | 359.8 | 609.8 | 615.4 | 935.8 | 542.5 | 658.7 | 894.1 |
| ចំណូលលើទ្រព្យសម្បត្តិ | 84.0 | 88.5 | 77.3 | 116.0 | 127.2 | 7.7 | 130.5 | 12.6 | 46.4 | 177.4 | 34.0 | 30.2 |
| លក់ទំនិញ និងសេវា | 750.3 | 871.2 | 1047.1 | 1248.3 | 1517.0 | 341.0 | 388.9 | 527.8 | 817.9 | 330.7 | 531.2 | 798.5 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 200.8 | 350.5 | 132.2 | 528.0 | 523.1 | 11.1 | 87.4 | 75.0 | 80.5 | 34.5 | 93.5 | 65.5 |
| ចំណូលជាមូលធន | 73.4 | 184.0 | 121.0 | 113.4 | 100.5 | 12.9 | 45.4 | 44.7 | 91.1 | 30.7 | 35.0 | 55.4 |
| ចំណាយសរុប | 12535.7 | 13306.5 | 13849.5 | 13775.4 | 17251.0 | 3583.2 | 4706.2 | 5861.4 | 4876.3 | 4150.4 | 4997.6 | 5386.5 |
| ចំណាយជាមូលធន | 5567.5 | 5590.7 | 5290.3 | 3785.3 | 5207.2 | 812.9 | 1517.8 | 1978.3 | 1421.2 | 1025.0 | 1392.7 | 1358.6 |
| ចំណាយចរន្ត | 6968.3 | 7715.8 | 8544.6 | 9990.1 | 12043.7 | 2770.3 | 3188.5 | 3883.1 | 3455.1 | 3125.4 | 3604.9 | 4027.9 |
| បៀវត្សរ៍ | 2997.3 | 3755.5 | 4271.9 | 5381.7 | 6647.4 | 1760.3 | 1911.1 | 2148.8 | 1738.3 | 1820.2 | 1911.1 | 2102.0 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 1563.0 | 1627.0 | 1742.9 | 1774.9 | 2314.8 | 469.9 | 621.1 | 597.2 | 817.2 | 729.2 | 1061.9 | 855.5 |
| ចំណាយចរន្តផ្សេងទៀត | 2408.0 | 2333.4 | 2529.8 | 2833.5 | 5394.3 | 1010.0 | 1277.4 | 1734.4 | 1716.9 | 1305.2 | 1693.8 | 1925.8 |
| សមតុល្យជាទូទៅ | -4280.6 | -2763.1 | -1969.6 | 426.1 | -669.1 | 774.5 | 374.4 | -1191.1 | 758.3 | 947.1 | 1359.6 | 978.0 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 4326.2 | 3972.1 | 3729.4 | 1878.9 | 3358.1 | 401.6 | 1064.4 | 413.1 | 634.4 | 652.8 | 895.5 | 608.8 |
| ហិរញ្ញប្បទានក្នុងស្រុក | 824.4 | -1428.7 | -2034.9 | -1858.7 | -2454.1 | 101.7 | 90.5 | -36.3 | 66.7 | -44.4 | -7.6 | 11.9 |

Source: Ministry of Economy and Finance website

## តារាង៦៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០១៣-១៩

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 3.0 | 3.9 | 1.2 | 3.1 | 2.9 | 2.3 | 2.7 | 2.5 | 2.4 | 1.9 | 1.9 | 1.8 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 3.9 | 4.9 | 4.0 | 5.6 | 3.4 | 1.9 | 2.9 | 2.5 | 2.5 | 2.1 | 2.1 | 1.6 |
| - ដឹកជញ្ជូន | -0.6 | -1.0 | -9.2 | -6.9 | 4.1 | 3.1 | 3.9 | 3.3 | 1.4 | -3.8 | -3.8 | -1.5 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4037.3 | 4036.2 | 4060.4 | 4053.7 | 4047.5 | 4012.4 | 4047.0 | 4073.7 | 4046.7 | 4006.6 | 4052.1 | 4086.8 |
| រៀលក្នុង ១ បាតថៃ | 133.1 | 124.9 | 119.4 | 115.5 | 120.0 | 127.7 | 127.4 | 124.2 | 124.2 | 127.4 | 128.9 | 133.7 |
| រៀលក្នុង ១០០ ដុងវៀតណាម | 19.3 | 19.1 | 18.7 | 18.2 | 17.9 | 17.8 | 17.9 | 17.7 | 17.5 | 17.4 | 17.5 | 17.7 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 175.9 | 152.3 | 140.6 | 151.2 | 151.5 | 160.3 | 157.6 | 146.1 | 147.3 | 156.6 | 157.1 | 175.7 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 5019.0 | 4852.1 | 3771.3 | 3004.0 | 3385.8 | 3679 | 3915.7 | 3784.3 | 3856.3 | 3413.9 | 3595.4 | 3499.7 |
| ថ្លៃសាំង (រៀល/លីត្រ) | 5264.2 | 5083.3 | 3951.7 | 3336.8 | 3716.0 | 3914 | 4120.3 | 4003.0 | 3893.0 | 3405.7 | 3770.2 | 3629.3 |

Sources: NIS, NBC; CDRI

## តារាង៧៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១៣-១៩ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 21260.1 | 26699.7 | 26665.5 | 31814.5 | 42575.3 | 46707.0 | 49421.9 | 52669.4 | 55214.3 | 58148.8 | 62699.5 | 67081.5 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 11508.3 | 15859.8 | 22157.6 | 25802.3 | 28743.5 | 28457.0 | 29926.1 | 31941.8 | 33228.9 | 33997.2 | 33548.0 | 34814.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2794.9 | -4359.1 | -6428.8 | -8148.5 | -11066.5 | -12381.1 | -12887.7 | -12996.4 | -14803.7 | -17381.0 | -18747.4 | -20263.2 |
| ឥណទានដល់វិស័យឯកជន | 27608.8 | 36244.6 | 46071 | 56458.8 | 66922.6 | 68686.5 | 72464.2 | 77925.6 | 82419.3 | 86574.4 | 91568.6 | 98320.3 |
| រូបិយវត្ថុទូទៅ | 32768.4 | 42559.5 | 48823.1 | 57616.6 | 71318.9 | 75164.0 | 79348.0 | 84611.3 | 88443.2 | 92146.0 | 96247.6 | 101895.8 |
| រូបិយវត្ថុ | 4878.2 | 6308.4 | 6741.4 | 7273.0 | 9428.4 | 9578.5 | 9553.9 | 10146.0 | 10226.8 | 10782.0 | 11274.5 | 13465.9 |
| រូបិយវត្ថុផ្សេងៗ | 21260.1 | 26699.7 | 42081.7 | 50343.8 | 61890.4 | 65585.5 | 69794.1 | 74465.2 | 78216.4 | 81364.0 | 84973.0 | 88429.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ | 14.6 | 29.9 | 14.7 | 18.0 | 23.8 | 24.1 | 21.6 | 21.3 | 24.0 | 22.6 | 21.3 | 20.4 |
| រូបិយវត្ថុ | 20.6 | 29.3 | 6.9 | 7.9 | 29.6 | 27.3 | 16.7 | 13.7 | 8.5 | 12.6 | 18.0 | 32.7 |
| រូបិយវត្ថុផ្សេងៗ | 13.6 | 30.0 | 16.1 | 19.6 | 22.9 | 23.7 | 22.3 | 22.4 | 26.4 | 24.1 | 21.7 | 18.8 |

Source: National Bank of Cambodia

## តារាង៨៖ ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយ ធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2017 | 2018 | | | | 2019 | | | | 2019 | | |
| | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នករត់ស៊ីក្លូ | 10793 | 11042 | 11285 | 10267 | 10503 | 11764 | 10567 | 11114 | 12046 | -6.4 | 8.2 | 14.7 |
| អ្នកលីសែង | 14942 | 15123 | 14915 | 15889 | 15454 | 15882 | 17323 | 16560 | 18802 | 16.1 | 4.2 | 21.7 |
| អ្នកលក់បន្លែតូចតាច | 17015 | 18343 | 20999 | 20141 | 21018 | 18912 | 21472 | 19197 | 18651 | 2.3 | -4.7 | -11.3 |
| អ្នករើសអេតចាយ | 11591 | 10664 | 13931 | 13288 | 12570 | 12941 | 12685 | 13123 | 13099 | -8.9 | -1.2 | 4.2 |
| អ្នករត់តុភោជនីយដ្ឋាន* | 22901 | 8226 | 8077 | 7945 | 8346 | 8299 | 8348 | 8564 | 8724 | 3.4 | 7.8 | 4.5 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 17341 | 8774 | 8486 | 8427 | 8984 | 8209 | 7909 | 9180 | 9376 | -6.8 | 8.9 | 4.4 |
| កម្មកររោងចក្រកាត់ដេរ | 14231 | 15268 | 14605 | 15316 | 15631 | 16073 | 15166 | 16076 | 16578 | 3.8 | 5.0 | 5.1 |
| អ្នករត់ម៉ូតូឌុប | 8093 | 14901 | 14429 | 15293 | 14637 | 14705 | 15104 | 14219 | 14904 | 4.7 | -7.0 | 1.8 |
| កម្មករសំណង់គ្មានជំនាញ | 8055 | 18082 | 15771 | 17539 | 18900 | 19820 | 17987 | 18322 | 18814 | 14.0 | 4.5 | -0.5 |
| កម្មករសំណង់មានជំនាញ | 14093 | 25578 | 25025 | 23276 | 26595 | 26265 | 24743 | 25235 | 27225 | -1.1 | 8.4 | 2.4 |

Notes: * Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. November 2015 data are not available. **Not available. Source: CDRI